# ការណែនាំផ្លូវ



លោកហាក់សាន់ថេលើ គឺជាអ្នកត្រួសត្រាយបេសកជនដ៏អស្ចារ្យម្នាក់បានសម្តែងចេញនូវគំនិតរបស់លោកអំពីការណែនាំផ្លូវ នៅពេលនោះលោកមានប្រសាសន៍ថាពេលដែលលោកកាន់តែចាស់ទុំជាគ្រិស្តបរិស័ទ ការណែនាំផ្លូវក៏កាន់តែពិបាក។ ជាញឹកញាប់ពេលទើបក្លាយជាគ្រិស្តបរិស័ទថ្មីៗ ព្រះជាម្ចាស់ហាក់បីដូចជាធ្វើឱ្យផ្លូវមើលទៅឃើញច្បាស់ ប៉ុន្តែក្រោយមកមានពេលខ្លះផ្លូវមើលទៅហាក់ដូចជាស្រពេចស្រពិល។ ព្រះជាម្ចាស់មាន បំណងផែនការនៅក្នុងការនេះ ។ ឧទាហរណ៍ ទារកមិនមានការទទួលខុសត្រូវធ្វើអ្វីទេ អ្វីៗគ្រប់យ៉ាងគឺឪពុកម្តាយជាអ្នកធ្វើទាំងអស់ ទារកមិនចាំបាច់ព្រួយបារម្ភនៅពេលណាត្រូវងូតទឹក ឬ ផ្លាស់ប្តូរខោទឹកនោមនោះឡើយ ប៉ុន្តែក៏មានការប្រែប្រួលទៅតាមពេលវេលាដែរ ។ ដូចគ្នានេះដែរ ព្រះជាម្ចាស់សព្វព្រះហរទ័យឱ្យយើងមានភាពចាស់ទុំនិងក្លាយជាគ្រិស្តបរិស័ទដែលមានទំនួលខុសត្រូវ



ដោយរៀនធ្វើការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ នៅពេលដែលយើងទុកចិត្តលើព្រះអង្គ ។ យើងទាំងអស់គ្នាសុទ្ធសឹងតែមានការប្រឈមមុខនឹងការសម្រេចចិត្តដែលពិបាកៗ ដោយសារយើងចង់ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលជាហេតុធ្វើឱ្យយើងមានការស្រពិចស្រពិល ថាតើការសម្រេចចិត្តណាមួយជាការសម្រេចចិត្តដែលត្រឹមត្រូវនោះ។ ខាងក្រោមនេះជាកត្តាដែលចង្អុរបង្ហាញដ៏មានប្រយោជន៍ ៖

## កត្តាមួយចំនួននៅក្នុងការធ្វើការសម្រេចចិត្ត

### ១. អារម្មណ៍ជាទូទៅ

ជាធម្មតាយើងមិនចាំបាច់សួរខ្លួនឯងនោះទេថា៖ "តើវាត្រឹមត្រូវដែរឬទេដែលត្រូវទទួលទានអាហារពេលព្រឹក ថ្ងៃត្រង់ ឬ ទឹកតែ?" ព្រះជាម្ចាស់បានបង្កើតរូបកាយយើងមកឱ្យពឹងផ្អែកលើម្ហូបអាហារ សម្រាប់ទ្រទ្រង់ដល់ការរស់រានមានជីវិត ដូច្នេះយើងត្រូវតែទទួលទានអាហារ ដើម្បីរក្សាសុខភាពឲ្យបានល្អ។ ការសម្រេចចិត្តទាំងនោះ គឺជាការសម្រេចចិត្តដែលច្បាស់លាស់។ ក៏គ្មានហេតុផលណាដែលត្រូវសួរទៅកាន់ព្រះជាម្ចាស់ថា តើយើងអាចលួចឡាន ឬ លួចយក ស្វាមី ឬភរិយារបស់នរណាម្នាក់បានដែរនោះទេ ដូចមានចែងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា៖ «កុំលួចប្លន់គេ» ហើយ «កុំប្រព្រឹត្តអំពើផិតក្បត់»។

### ២. ការអត់ធ្មត់

មានពេលខ្លះដែលខ្ញុំបានអធិស្ឋានថា៖ «ព្រះអម្ចាស់អើយថ្ងៃនេះ ព្រះអង្គត្រូវបង្ហាញពីបំណងព្រះហឫទ័យរបស់ព្រះអង្គអំពីអនាគតទូលបង្គំ។ល។ ជារឿយៗព្រះអង្គមិនបំពេញតាមការទាមទារទាំងនេះទេ។ ម្យ៉ាងវិញទៀតនៅពេលដែលខ្ញុំពិតជាត្រូវការ ដឹងពីបំណងព្រះហឫទ័យរបស់ព្រះអង្គអំពីអ្វីមួយនោះព្រះអង្គក៏មានបន្ទូលមកខ្ញុំដោយចំពេលវេលាដែលត្រឹមត្រូវ។ ជាញឹកញាប់វាជានាទីចុងក្រោយ! ការរង់ចាំ គឺជាបទពិសោធដ៏សំខាន់មួយដែលត្រូវរៀនសូត្រ។

### ៣. ទីប្រឹក្សា

ទីប្រឹក្សាមានសារៈសំខាន់ណាស់ ដូចនៅក្នុងកណ្ឌគម្ពីរសុភាសិតថែងថា៖*.... រីឯប្រទេសដែលមានទីប្រឹក្សាច្រើន តែងតែមានជោគជ័យ។” សុភាសិត* ១១:១៤ ។

អ្នកពិគ្រោះយោបល់គ្រិស្តបរិស័ទ គួរតែមានទស្សនៈរបស់ព្រះជាម្ចាស់ទៅតាមស្ថានភាពខុសៗគ្នា ប៉ុន្តែចូរចងចាំថា មនុស្សមិនមែនជាអ្នកដែលមិនចេះធ្វើខុសនោះទេ! នៅគ្រាមួយ ខ្ញុំនិងភរិយាត្រូវបានអញ្ជើញឱ្យឃ្វាលក្រុមជំនុំមួយ។ យើងមិនបានព្រមព្រៀងគ្នាទេថា តើយើងគួរតែទៅឬយ៉ាងណា បើទោះជាពេលនោះខ្ញុំមិនមានការងារបិតបេរក៏ដោយ។ ដោយការស្វែងរកដំបូន្មានពីបុរសដែលកោតខ្លាចព្រះម្នាក់ ដែលខ្ញុំគោរពឲ្យតម្លៃយ៉ាងខ្លាំង គាត់មានអារម្មណ៍ថា (ដោយការពិចារណាថ្លឹងថ្លែងល្អិតល្អន់) វាជាការដែលត្រឹមត្រូវដែលត្រូវទទួលយកកិច្ចការនោះ។ ប៉ុន្តែមានប្ដីប្រពន្ធមួយគូទៀតជាគ្រិស្តបរិស័ទថ្មី ពេលនោះបានណែនាំពួកយើងឱ្យរង់ចាំ រហូតទាល់តែយើងប្រាកដនៅក្នុងចិត្ត។ ទោះវាមិនមែនជារឿងប្រក្រតីក៏ដោយ ពេលវេលាបានបង្ហាញថា គូស្វាមីភរិយាចុងក្រោយនេះ បានផ្ដល់ដំបូន្មានយ៉ាងត្រឹមត្រូវ មិនមែនជាបុរសវ័យចំណាស់ដែលគោរពកោតខ្លាចព្រះជាម្ចាស់នោះទេ។ ប៉ុន្តែទោះបីជារយៈពេលវែង ឬ ខ្លីក៏ដោយ អ្នកដែលត្រូវទទួលខុសត្រូវចំពោះការសម្រេចចិត្តចុងក្រោយបង្អស់ គឺជារូបអ្នកផ្ទាល់ មិនមែនជាអ្នកផ្សេងនោះទេ។ ការសម្រេចចិត្តសំខាន់ៗត្រូវមានការព្រមព្រៀងគ្នារវាង ស្វាមី និង ភរិយា។ សូមចងចាំថាព្រះជាម្ចាស់ យកព្រះទ័យទុកដាក់ពីអនាគតរបស់លោកអ្នកច្រើនជាងលោកអ្នកទៅទៀត ។

*« យើងនឹងប្រៀនប្រដៅណែនាំអ្នក ឲ្យស្គាល់ផ្លូវដែលអ្នកត្រូវដើរ យើងនឹងជួយឲ្យយោបល់អ្នក ព្រមទាំងមើលថែទាំអ្នកផង។ ទំនុកតម្កើង ៣២:៨*

តើព្រះបន្ទូលអ្វី ដែលមានបន្ទូលមកលោកយេរេមា? *សូមអានយេរេមា១:៥*

________________________________________

តើព្រះបន្ទូលអ្វី ដែលមានបន្ទូលមកលោកប៉ូល? *សូមអាន កាឡាទី ១:១៥*

________________________________________

តាមការបំភ្លឺរបស់បទគម្ពីរខាងលើខ្ញុំជឿជាក់ថា ព្រះនឹងដឹកនាំយើងទៅក្នុងការសម្រេចចិត្តដែលសំខាន់ៗ



ដូចជាការទិញឡាន ឬ ផ្ទះ ការជ្រើសរើសដៃគូអាពាហ៍ពិពាហ៍ ឬ ការឈប់សម្រាកលំហែកាយ ប្រសិនជាការរំពឹងទុករបស់យើងគឺបែបនោះ ។

**គោលការណ៍បីសំខាន់ៗ**

មានគ្រិស្តបរិស័ទរាប់ពាន់នាក់មកហើយបានរកឃើញថា ចំណុចទាំងនេះពិតជាមានប្រយោជន៍ នៅពេលដែលពួកគេស្វែងរកការណែនាំផ្លូវ ។

### ១. ព្រះគម្ពីរ

*«ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំ ។» ទំនុកដំកើង ១១៩: ១០៥*

វាជាការអស្ចារ្យណាស់

ដែលព្រះគម្ពីរអាចមានបន្ទូលមកកាន់យើងដែលត្រូវនឹងស្ថានភាពក្នុងពេលបច្ចុប្បន្ននេះ ។

មានអ្នកអានព្រះគម្ពីរចំនួន ៤ ប្រភេទ៖
អ្នកដែលស្វែងរកការជជែកវែកញែក ។
អ្នកដែលដាក់កំហិតទៅតាមដែលកំណត់នៃគំនិតប្រាថ្នារបស់គេ ។
អ្នកដែលអានព្រះគម្ពីរ ទុកដូចជាសៀវភៅរឿងនានា ។
អ្នកដែលអានព្រះគម្ពីរដោយយកខ្លួនឯងធ្វើជាប្រធានបទ ទាំងបើកចិត្ត ព្រមទាំងស្ដាប់តាមការបង្រៀនរបស់ព្រះគម្ពីរ ។

### ២. ត្រូវមានសេចក្ដីសុខសាន្តនៅក្នុងវិញ្ញាណរបស់អ្នក

នេះមិនមែនមានន័យថា យើងនឹងមិនមានការថប់ព្រួយ នៅពេលដែលជួបនឹងកិច្ចការស្មុគស្មាញណាមួយនោះទេ ។

*ព្រះយេស៊ូមានបន្ទូលថា៖ “ខ្ញុំទុកសេចក្ដីសុខសាន្តឲ្យអ្នករាល់គ្នា ខ្ញុំផ្ដល់សេចក្ដីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់គ្នា។ សេចក្ដីសុខសាន្តដែលខ្ញុំផ្ដល់ឲ្យនេះ មិនដូចសេចក្ដីសុខសាន្តដែលមនុស្សលោកឲ្យទេ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចឲ្យសោះ ។ យ៉ូហាន ១៤:២៧*

មានពេលខ្លះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់យើង ហាក់ដូចជាមិនសមហេតុផលសោះ ខ្ញុំជឿជាក់ថាលោកអ័ប្រាហាំក៏ពិតជាមានការស្រពិចស្រពិលដែរ នៅពេលដែលព្រះជាម្ចាស់មានបន្ទូលប្រាប់គាត់ឱ្យចាកចេញពីកន្លែងដែលចម្រុងចម្រើន ហើយឲ្យទៅកន្លែងដែលលោកមិនស្គាល់ *(លោកុប្បត្តិ ១២:១)* ។

ប៉ុន្មានឆ្នាំក្រោយមក បើតាមការក្រឡេកមើលទៅក្រោយវិញ ខ្ញុំជឿជាក់ថាលោកអ័ប្រាហាំ
អាចមើលឃើញពីរបៀបនៃការបង្កើតឱ្យមានការជឿទុកចិត្តនេះ
ទៅលើព្រះដ៏ពិតតែមួយដែលមាននៅក្នុងលោក ។

**៣. កាលៈទេសៈ**

វាមិនអាចទៅរួចទេ
ដែលព្រះជាម្ចាស់សព្វព្រះហរទ័យឲ្យលោកអ្នកធ្វើដំណើរ
ប្រសិនបើលោកអ្នកជាមនុស្សដេកឈឺនៅតែលើគ្រែនោះ ឬ អោយលោកអ្នកចាកចេញពីការងារមួយ ហើយទៅធ្វើការងារកន្លែងមួយទៀត
ប្រសិនជាលោកអ្នកកំពុងតែស្ថិតនៅក្រោមកិច្ចសន្យាការងារ
ការធ្វើខុសច្បាប់ការងារដែលនាំឱ្យព្រះនាមរបស់ព្រះជាម្ចាស់ទៅជាអាប់អោននោះទេ ។ កិច្ចការភាគច្រើន នឹងដំណើរការទៅបានដោយរលូន
នៅពេលដែលពេលវេលាត្រឹមត្រូវមកដល់។

គោលការណ៍ទាំងនេះ ជួយដល់ជីវិតរស់នៅរបស់គ្រិស្តបរិស័ទ
ប៉ុន្តែវាជាការខុសឆ្គងសម្រាប់ការដាក់ដែនកំណត់ព្រះជាម្ចាស់
សំរាប់តែគោលការណ៍ ទាំងនេះ។
ដូច្នេះសូមបើកចិត្តសម្រាប់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលជា "អ្នកប្រឹក្សា" ដើម្បីនាំទៅរកសេចក្តីពិតសព្វគ្រប់ ។

នៅក្នុងលោកុប្បត្តិ ២៤
គោលការណ៍ទាំងបីនេះត្រូវបានបំភ្លឺនៅក្នុងជីវិតរបស់អ្នកបំរើព្រះ
ហើយបញ្ជាក់នៅក្នុងខគម្ពីរត្រឹមត្រូវទាំងនេះ៖

| |
|---|
| ព្រះបន្ទូលរបស់ព្រះអម្ចាស់ (តាមរយៈម្ចាស់របស់គាត់) ________________ |
| សន្តិភាព នៅក្នុងវិញ្ញាណរបស់គាត់ ________________ |
| កាលៈទេសៈដែលត្រឹមត្រូវ ________________ |

## ការថ្លែងព្រះបន្ទូល និង ការណែនាំផ្លូវ

ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ប្រជារាស្ត្ររបស់ព្រះអង្គ
តាមរយៈអំណោយទាននៃការថ្លែងព្រះបន្ទូល។
ការលើកឡើងអំពីអំណោយទាននេះគឺមាននៅក្នុង *១ កូរិនថូស ជំពូក ១២ និង ១៤* ។ មនុស្សដែលបានបណ្តាលដោយព្រះវិញ្ញាណនៅក្នុងការថ្លែងព្រះបន្ទូលមកពីព្រះអម្ចាស់ ។ សូមអាន ឧទាហរណ៍ នៅក្នុង *កិច្ចការ ១៣:១-៣* ជាការកម្រណាស់ដែលការថ្លែងព្រះបន្ទូលផ្តល់មកជាជំហានដំបូងនៅក្នុងការណែនាំផ្លូវ។
ជារឿយៗការថ្លែងព្រះបន្ទូលជាការគាំទ្រនូវអ្វីដែលយើងដឹងនៅក្នុងចិត្តថាព្រះជាម្ចាស់កំពុងតែប្រាប់យើងឱ្យធ្វើ។
ជាញឹកញាប់តែងមានបុគ្គលរឹងមាំណាម្នាក់ចែកចាយពាក្យថ្លែងព្រះបន្ទូលដាក់ទម្ងន់លើព្រះរាជសារ ដោយប្រុងប្រយ័ត្ន និងមានឆន្ទៈក្នុងការចែកចាយជាព្រះបន្ទូលបែបនេះជាមួយអ្នកដទៃសំរាប់ជាការអះអាងបញ្ជាក់ ។

## សេចក្តីសន្និដ្ឋាន

ដរាបណាការណែនាំផ្លូវជាផ្នែកមួយនៅក្នុងជីវិតមនុស្ស
នោះក៏ជាឱកាសដែលបង្កើតឲ្យមានកំហុសកើតឡើងដែរ។
បើមានរឿងបែបនេះកើតឡើង សូមកុំមានការស្លន់ស្លោ ឬថ្កោលទោសខ្លួនឯងនោះឡើយ។ សូមសារភាពពីស្ថានភាពនោះថ្វាយទៅព្រះជាម្ចាស់ចុះ
ហើយស្វែងរកបំណងព្រះហឫទ័យរបស់ទ្រង់សាជាថ្មីវិញ ។

> គ្រូគង្វាល និងអ្នកចាស់ទុំនៅក្នុងក្រុមជំនុំរបស់លោកអ្នក
> គួរតែជាអ្នកដែលអាចផ្តល់ការប្រឹក្សាយោបល់ឲ្យបាន
> ប្រសិនបើលោកអ្នកជឿជាក់ថាព្រះជាម្ចាស់កំពុងត្រាស់ហៅលោកអ្នក
> ឱ្យចូលទៅក្នុងកិច្ចការបម្រើគ្រិស្តបរិស័ទឲ្យកាន់តែសកម្មនោះ។
> ដំបូន្មានរបស់ពួកគាត់អាចជាដំបូន្មានដែលមានតម្លៃបំផុត ។

*“ព្រះអម្ចាស់ពង្រឹងជំហានរបស់មនុស្សឲ្យបានមាំមួន ហើយព្រះអង្គគាប់ព្រះហឫទ័យនឹងមាគ៌ារបស់គេ ។ ប្រសិនបើអ្នកនោះភ្លាត់ជើង គេនឹងមិនដួលដល់ដីឡើយ ព្រោះព្រះអម្ចាស់កាន់ដៃគេជាប់។ ទំនុកតម្កើង ៣៧:២៣-២៤*